# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ០១៣០៧ ព.ណ.តសម

ថ្ងៃ ចន្ទ ១០កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០២២

**ជម្រាបមក**

**លោក/លោកស្រីប្រធានក្រុមហ៊ុន ឈរ ប៊ុន សាម អ៊ិនវេសមេន ឯ.ក**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលស្ករគ្រាប់ (Candy) នំធ្វើពីស្ករគ្រាប់ (Candy Cake) ស្ករគ្រាប់រសជាតិជីរអង្កាម (Peppermint Candy) ស្ករគ្រាប់រសជាតិហិរ (Candy Mint) ស្ករគ្រាប់ ទឹកកក (Ice Candy) ស្ករគ្រាប់រសជាតិពោត (Corn Candy) ស្ករគ្រាប់រសជាតិខារ៉ាមែល (Caramel Candy) ស្ករគ្រាប់លាយជាមួយកាកាវ (Candy with Cacao) ស្ករគ្រាប់មានស្រោបស្កររោយ (Candy Coat with Confections) ស្កររសជាតិពោតលីង (Sugar Coated Popcorn) ស្ករសម្រាប់តុបតែង (Candy Cake Decoration) ស្ករគ្រាប់លាយជាមួយស្ករខារ៉ាមែលគ្មានជាតិថ្នាំ (Candy with Caramel Candy Non-medicated) ស្ករចាហួយ រសជាតិផ្លែឈើគ្មានជាតិថ្នាំ (Fruit Jelly Candy Non-Medicated) ស្ករកៅស៊ូ (Chewing Gum) ស្កររោយគ្មាន ជាតិថ្នាំ (Non-medicated confectionery Candy) ស្ករគ្រាប់ (Sugar Candy) ស្ករគ្រាប់តុបតែងនំខេក (Candy Decorated for Cake) ម៉ាក (T-Milk) របស់ក្រុមហ៊ុន **ឈរ ប៊ុន សាម អ៊ិនវេសមេន ឯ.ក** ក្នុងព្រះរាជាណាចក្រកម្ពុជា។

**យោង:**- មាត្រា ៣ និងមាត្រា ១១នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **ឈរ ប៊ុន សាម អ៊ិនវេសមេន ឯ.ក** ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០២១
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន TS BETTER FOODS CO., LTD. ចុះថ្ងៃទី 04 ខែវិច្ឆិកា ឆ្នាំ ២០២១
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៧០១២៩/១៨ ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០១៨។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលស្ករគ្រាប់ (Candy) នំធ្វើពីស្ករគ្រាប់ (Candy Cake) ស្ករគ្រាប់រសជាតិជីរអង្កាម (Peppermint Candy) ស្ករគ្រាប់រសជាតិហិរ (Candy Mint) ស្ករគ្រាប់ ទឹកកក (Ice Candy) ស្ករគ្រាប់រសជាតិពោត (Corn Candy) ស្ករគ្រាប់រសជាតិខារ៉ាមែល (Caramel Candy) ស្ករគ្រាប់លាយជាមួយកាកាវ (Candy with Cacao) ស្ករគ្រាប់មានស្រោបស្កររោយ (Candy Coat with Confections) ស្កររសជាតិពោតលីង (Sugar Coated Popcorn) ស្ករសម្រាប់តុបតែង (Candy Cake Decoration) ស្ករគ្រាប់លាយជាមួយស្ករខារ៉ាមែលគ្មានជាតិថ្នាំ (Candy with Caramel Candy Non-medicated) ស្ករចាហួយរសជាតិផ្លែឈើគ្មានជាតិថ្នាំ (Fruit Jelly Candy Non-Medicated) ស្ករកៅស៊ូ (Chewing Gum) ស្កររោយគ្មាន ជាតិថ្នាំ (Non-medicated confectionery Candy) ស្ករគ្រាប់ (Sugar Candy) ស្ករគ្រាប់តុបតែងនំខេក (Candy Decorated for Cake) ពាក់ម៉ាកខាងលើរបស់ក្រុមហ៊ុន **ឈរ ប៊ុន សាម អ៊ិនវេសមេន ឯ.ក** ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានពីក្រុមហ៊ុន TS BETTER FOODS CO., LTD. ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះមានសុពលភាពរយៈពេល ០២(ពីរ) ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន TS BETTER FOODS CO., LTD. ដែលជាម្ចាស់ម៉ាក។

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ८៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

ចាប់ពីក្រោយរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះអ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានា ហើយត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**

***<u>ចម្លងជូន:</u>***

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប)*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ - កាលប្បវត្តិ*